**ការធ្វើ តែស្ត កូវីដ ទៅកាន់សិស្សនឹងផ្អាកមួយសប្តាហ៍**

ជម្រាបជូនសហគមន៍សាលារៀន ឡុងប៊ីច,

សូមអរគុណចំពោះជំនួយគាំទ្រពីលោកអ្នកមកលើការជួយយើងខ្ញុំបើកសាលារៀនឡើងវិញដោយជោគជ័យ ដែលមានសិស្សចូលរៀននៅតាមថ្នាក់ផ្ទាល់ - និង នៅតែបើក - សម្រាប់ឆមាសនៃរដូវស្លឹកឈើធ្លាក់ ។ ជាពិសេស គឺយើងខ្ញុំសូមថ្លែងអំណរគុណចំពោះការអត់ធ្មត់នៃសិស្ស និង បុគ្គលិក នៅពេលយើងខ្ញុំបានធ្វើ តែស្ត កូវីដ-១៩ ដែលមិនបង្ហាញជារោគសញ្ញា ទៅកាន់សិស្សមិនទាន់ចាក់ថ្នាំ វ៉ាក់ស៊ីន ក្នុងរយៈពេល បី សប្តាហ៍ដំបូងនៃឆ្នាំសិក្សា ។ មកទល់ឥឡូវនេះ គឺយើងខ្ញុំបានធ្វើ តែស្ត ប្រហែល 60,000 ដង ដែលមានការបង្ហាញលទ្ធផលជា វិជ្ជមាន (positive) តិចជាងកម្រិត 1% ។ លទ្ធផលជាកម្រិតទាបនេះ គឺជាសេចក្តីបញ្ជាក់អំពីកិច្ចការប្រឹងប្រែងនៃក្រុមគ្រួសារ សិស្ស និង បុគ្គលិក ដែលបានបង្ហាញជាងប៉ុន្មានសប្តាហ៍កន្លងមក ។

ដូចលោកអ្នកជ្រាបហើយ ការធ្វើ តែស្ត តាមលក្ខណៈមិនបង្ហាញជារោគសញ្ញា គឺជាមធ្យោបាយម្យ៉ាងក្នុងចំណោមមធ្យោបាយស្ទង់វាស់ជាច្រើនយ៉ាង ដែលបានចាត់ចែងធ្វើឡើងសម្រាប់ដោះស្រាយជម្ងឺ កូវីដ-១៩ ដែលអាចកើតមាននៅក្នុងសាលារៀនរបស់យើង ។ **ឥឡូវនេះ យើងខ្ញុំមានគម្រោងផ្អាកសិនអំពីការធ្វើ តែស្ត រយៈមួយសប្តាហ៍ នៅពេលយើងខ្ញុំវែកញែកមើលជាបន្ថែមអំពីទិន្នន័យក្នុងការជួបពិគ្រោះជាមួយមន្ត្រីផ្លូវការប្រចាំក្រសួងសុខាភិបាល ហើយយើងខ្ញុំនឹងជម្រាបជូនលោកអ្នកអំពីគម្រោងសម្រាប់ធ្វើជាបន្ត នៅពេលឈានដំណើរទៅមុខ ។**

ម្តងទៀត យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការប្រឹងប្រែងដ៏អស្ចារ្យ ដែលសហគមន៍បានជួយមកកាន់យើងខ្ញុំអំពីការនាំសិស្សត្រឡប់ចូលនៅតាមបន្ទប់រៀនវិញ ដែលជាកន្លែងសម្រាប់ពួកគេរៀន និង បង្ហាញភាពលូតលាស់ដ៏ល្អបំផុត ។

ដោយសេចក្តីអំណរគុណយ៉ាងជ្រៅជ្រះ,

Jill

Jill A. Baker, Ed. D.
អគ្គនាយកសាលារៀន